មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍រួម
# រវាងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានិងគណៈកម្មាធិការសិទ្ធិមនុស្សអាស៊ី

ភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩

## របាយការណ៍រួមសំរាប់ការត្រួតពិនិត្យជាសកលតាមពេលកំណត់ (UPR) ស្តីអំពីបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា៖ សេរីភាពបញ្ចេញមតិ និងការជួបប្រជុំនៅកម្ពុជាទទួលនូវការរំលោភយ៉ាងខ្លាំង

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) និងគណៈកម្មាធិការសិទ្ធិមនុស្សអាស៊ី (AHRC) សូមជំរាបជូនថា សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលមួយដែលសម្របសម្រួលដោយសម្ព័ន្ធភាពដើម្បីសេរីភាពបញ្ចេញមតិនៅកម្ពុជា (AFEC) និងជំនួយដោយមជ្ឈមណ្ឌលផ្នែកច្បាប់អាស៊ី (ALRC) បានរៀបចំរបាយការណ៍រួមមួយស្តីពីសេរីភាពបញ្ចេញមតិ និងការជួបប្រជុំនៅកម្ពុជាដើម្បីដាក់ជូនទៅការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សនៅទីក្រុងហ្សឺណែវ សំរាប់ដាក់បញ្ចូលនៅក្នុងរបាយការណ៍សង្ខេបរបស់ខ្លួនស្តីអំពីពត៌មាន ដែលបានមកពីស្ថាប័នពាក់ព័ន្ធ។ របាយការណ៍នេះនឹងក្លាយជា ពត៌មានសំរាប់ការត្រួតពិនិត្យជាសកលតាមពេលកំណត់ស្តីពីបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា។

របាយការណ៍រួមនេះបានបង្ហាញថា ក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ សេរីភាពបញ្ចេញមតិនិងការជួបប្រជុំនៅកម្ពុជាទទួលនូវការរំលោភយ៉ាងខ្លាំង ដោយក្នុងនោះមាន៖ ការរឹតត្បិតការបញ្ចេញមតិ ការបំបិទមាត់អ្នកតំណាងរាស្ត្រ ការត្រួតពិនិត្យលើប្រព័ន្ធផ្សព្វផ្សាយ ការទទួលបានពត៌មានត្រូវបានគេទប់ស្កាត់ ហើយការជួបប្រជុំនិងបាតុកម្មតាមទីសាធារណៈត្រូវបានហាមឃាត់។ រាជរដ្ឋាភិបាលកម្ពុជាបានរំលោភលើកាតព្វកិច្ចអន្តរជាតិនិងរដ្ឋធម្មនុញ្ញដែលមានចែងអំពីសិទ្ធិមនុស្ស និងប្រើប្រាស់នូវរាល់ច្បាប់ជាតិទាំងឡាយដែលផ្ទុយនឹងកាតព្វកិច្ចទាំងនេះ។

ដើម្បីធ្វើឲ្យស្ថានភាពនេះមានភាពប្រសើរឡើង សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលនេះទទូចឲ្យរាជរដ្ឋាភិបាលគោរពឲ្យបានម៉ត់ចត់លើសេរីភាពបញ្ចេញមតិនិងការជួបប្រជុំ និងអនុវត្តនូវអនុសាសន៍ មួយចំនួនដូចខាងក្រោយ៖

1. ឲ្យសច្ចាប័នលើពិធីសារតាមចិត្តជ្រើសរើសទី១ ជាប់នឹងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដើម្បីអនុញ្ញាតិឲ្យពលរដ្ឋកម្ពុជាគ្រប់រូបអាចដាក់ពាក្យបណ្តឹងទៅដល់គណៈកម្មការសិទ្ធិមនុស្ស ទាក់ទងនឹងការរំលោភសិទ្ធិសេរីភាពបញ្ចេញមតិនិងការជួបប្រជុំ និងសិទ្ធិដទៃទៀត។

ផ្ទះលេខ៧៨៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។
ទូរស័ព្ទលេខ: (855) 23 726 901 ទូរសារ: (855) 23 726 902, អ៊ីមែល: info@cchrcambodia.org,
គេហទំព័រ: www.cchrcambodia.org

2. អញ្ជើញអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការពារសិទ្ធិសេរីភាពបញ្ចេញមតិមកធ្វើទស្សនកិច្ច និងវាយតំលៃលើស្ថានភាពនៅកម្ពុជានិងផ្តល់ជាអនុសាសន៍។
3. ធ្វើការជាមួយរដ្ឋសមាជិកដទៃទៀតរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ដើម្បីបង្កើតឲ្យបាននូវស្ថាប័នសិទ្ធិមនុស្សអាស៊ានមួយនៅក្នុងឆ្នាំ២០០៩។
4. បង្កើតឲ្យបាននូវគណៈកម្មាធិការសិទ្ធិមនុស្សជាតិឯករាជ្យមួយក្នុងឆ្នាំ២០០៩ ដើម្បីឲ្យស្របតាមគោលការណ៍នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។
5. ទទួលយកជាសាធារណៈនូវគោលការណ៍ទីក្រុងជហាណាសបឺក(Johannesburg) និងធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីបង្កើតឲ្យបាននូវយុទ្ធសាស្រ្តស្តីពីសេរីភាពបញ្ចេញមតិនិងការជួបប្រជុំក្នុងនាមជាផ្នែកមួយ នៃផែនការសកម្មភាពផ្នែកសិទ្ធិមនុស្សរួម។
6. លុបចោលបទល្មើសក្នុងការផ្សាយពត៌មានមិនពិត និងបរិហាកេរ្តិ៍ពីច្បាប់ព្រហ្មទណ្ឌថ្មីដែលកំពុងធ្វើ។
7. អញ្ជើញអ្នកជំនាញការរាប់បញ្ចូលទាំងអង្គការមាត្រា១៩ (Article 19) និងអង្គការអប់រំវិទ្យាសាស្រ្ត និងវប្បធម៌សហប្រជាជាតិ (UNESCO) ដើម្បីវាយតំលៃនិងផ្តល់អនុសាសន៍ ដើម្បីធ្វើវិសោធនកម្មលើច្បាប់ស្តីពីរបបសារពត៌មានឆ្នាំ១៩៩៥ និងច្បាប់បាតុកម្មឆ្នាំ១៩៩១ និងអនុវត្តនូវច្បាប់ថ្មីទាំងនេះ។

សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដែលចូលរួមធ្វើរបាយការណ៍នេះរួមមាន៖
វិទ្យស្ថានតស៊ូមតិ និងគោលនយោបាយ(API) មជ្ឈមណ្ឌលផ្នែកច្បាប់អាស៊ី(ALRC) សមាគមអាដហុកការពារសិទ្ធិមនុស្សនិងអភិវឌ្ឍនៅកម្ពុជា (ADHOC) សមាគមកម្ពុជាដើម្បីការពារអ្នកសារពត៌មាន(CAPJ) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR) សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា (CITA) សមាគមមន្ត្រីរាជការឯករាជ្យ (CICA) សម្ព័នជំរឿនការពារសិទ្ធិមនុស្សលីកាដូ (LICADHO) មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) មជ្ឈមណ្ឌលដើម្បីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(CCPR) សម្ព័នសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា(C-CAWDU) គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរីនិងយុត្តិធម៌នៅកម្ពុជា (COMFREL) មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC) សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា(FTUWKC) សមាគមប្រជាធិបតេយ្យឯករាជ្យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) សហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស (FIDH) សមាគមខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស (KKKHRA) ជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) គណៈកម្មាធិការអព្យាក្រិតនិងមិនលំអៀងសំរាប់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (NECFEC) មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍(PDP-Center) អង្គការប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ(PADV) សម្ព័ន្ធសារពត៌មានអាស៊ីអគ្នេយ៍ (SEAPA) និងស្តារកម្ពុជា(Star Kampuchea)។

របាយការណ៍ទាំងមូល អាចរកបាននៅក្នុងគេហទំព័រ www.cchrcambodia.org ។

ផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។
ទូរស័ព្ទលេខ: (855) 23 726 901 ទូរសារ: (855) 23 726 902, អ៊ីមែល: info@cchrcambodia.org,
គេហទំព័រ: www.cchrcambodia.org